ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ៣៤ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

០១-៩-១៩៩៥ – ព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ច្បាប់ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ១៧៥៤

II. ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៩-៩-១៩៩៥ – អនុក្រឹត្យលេខ ៦៧ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនកម្ពុជា – ថៃ ១៧៧១

២០-៩-១៩៩៥ – អនុក្រឹត្យលេខ ៦៨ អនក្រ. បក ស្តីពីការបង្កើតមន្ទីរប្រឆាំងគ្រឿងញៀន ១៧៧៦

២១-៩-១៩៩៥ – អនុក្រឹត្យលេខ ៦៩ អនក្រ. បក ស្តីពីការបង្កើតសាលាកសិកម្មកំពង់ចាម ១៧៧៨

១៨-៩-១៩៩៥ – អនុក្រឹត្យលេខ ១០៥ អនក្រ. ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៨១

១៨-៩-១៩៩៥ – អនុក្រឹត្យលេខ ១០៦ អនក្រ. ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៨២

២០-៩-១៩៩៥ – អនុក្រឹត្យលេខ ១០៧ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៨៣

២១-៩-១៩៩៥ – អនុក្រឹត្យលេខ ១០៨ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីជាកុងស៊ុលព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុង ១៧៨៤

២-សារាចរ

២០-៩-១៩៩៥ – សារាចរលេខ ០៦ សរ ស្តីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងតម្រប់ព្រះជន្ម ៧៣ យាងចូល ៧៤ ព្រះវស្សា បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក និងបុណ្យខួបអនុស្សាវរីយ៍លើកទី ៤២ នៃទិវាបុណ្យឯករាជជាតិ ៩ វិច្ឆិកា ១៧៨៥

III - ការងារបណ្ដាក្រសួង

១-នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

១៨-៩-១៩៩៥ – ប្រកាសលេខ ៧១៩ ឧក.ប្រក. អនុញ្ញាតអោយលោក **ឈឹម គឹក** ជនជាតិខ្មែរបន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤សេះ ១៧៩០

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២០ ឧក.ប្រក. អនុញ្ញាតអោយលោក **ឃោ ឃាត់** ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៨០សេះ ១៧៩០

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២១ ឧក.ប្រក. អនុញ្ញាតអោយលោក **ថាយ សេងឡេង** ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ១៧៩១

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២២ ឧក.ប្រក អនុញ្ញាតអោយលោក **ទ៉េង ឆាយ** ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ ១៧៩១

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២៣ ផក.ប្រក អនុញ្ញាតអោយលោក ខាមខឹង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ ១៧៩២

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២៤ ផក.ប្រក អនុញ្ញាតអោយលោក ម៉ិត ខុម ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម ១៧៩៣

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២៥ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុំ គុង ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកក្បុង «រូបជី» ១៧៩៣

១៨-៩-១៩៩៥ – ប្រកាសលេខ ៧២៦ ផក. ប្រក អនុញ្ញាតអោយអ្នកស្រី ហុង គីមស្រ៊ុន ជនជាតិខ្មែរ បើកដំណើរការឡឥដ្ឋក្បឿង ១៧៩៣

២-ស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៩-៩-១៩៩៥ – ប្រកាសលេខ ២៣៧/៩៥ ពម.ប្រក ស្តីពីការផ្ទេរមន្ត្រី រាជការរបស់ក្រសួងពតិមាន ១៧៩៤

៣-ឥស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

១៩-៩-១៩៩៥ – ប្រកាសលេខ ១៦១ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រី រាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តតាកែវ ១៧៩៥

៤-ឥស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៥-៩-១៩៩៥ – ប្រកាសលេខ ១៤៩៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋម

	សិក្សា ៧ មករា មកជាសាលាបឋមសិក្សា ពេជ្រមន្ត្រី	១៧៩៦
២០–៩–១៩៩៥	– ប្រកាសលេខ ១៥៩៨ អយក.ប្រក ស្តីពីការទទួលស្គាល់សិស្ស និងក្រុមសិស្សពូកែ ទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ និងគណិតវិទ្យា នៃមធ្យមសិក្សា សំរាប់ឆ្នាំសិក្សា ១៩៩០–១៩៩៥	១៧៩៨
១៩–៩–១៩៩១	– ប្រកាសលេខ ១៥០២ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យអំពិលទៅជា «អនុវិទ្យាល័យសម្តេច ជា ស៊ីម »នៅខេត្តស្វាយរៀង	១៨០២

៥-ឯកសារក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២១–៩–១៩៩៥	– សេចក្តីសំរេចលេខ ១៨៩/៩៥កធស ស្តីពីការអនុញ្ញាតច្បាប់ទទួលស្គាល់គ្រិស្តសាសនា នៃ «ក្រុមជំនុំព្រះគុណ»	១៨០៣
២២–៩–១៩៩៥	– សេចក្តីសំរេចលេខ ១៩០/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់អោយបើកស្នាក់សាខាអង្គការនិស្សិត និងប្រជារាស្ត្រខ្មែរថ្វាយព្រះគ្រិស្ត «នៅខេត្តពោធិសាត់»	១៨០៥
២២–៩–១៩៩៥	– ប្រកាសលេខ ១៩១/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨០៦

៦-ឯកសាររដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

២០–៩–១៩៩៥	– ប្រកាសលេខ ១១០ ប្រក.ផក ស្តីពីទទួលស្គាល់ការិយាល័យផែនការក្រុងកែប មកជាមន្ទីរផែនការ ក្រុងកែប	១៨០៧

៧-ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២២–៩–១៩៩៥ – ប្រកាសលេខ ១៥២ បទ ស្តីពីការផ្ទេរមន្ត្រី បុគ្គលិក រាជការ ១៨០៨

១៨–៩–១៩៩១ – ប្រកាសលេខ ១២០ បទ.ប្រក អនុញ្ញាតអោយលោក ម៉េង នោ ផ្អាកឈប់ប្រើប្រាស់វិទ្យុទាក់ទង ប្រភេទ HF ១៨១០

១៨–៩–១៩៩១ – ប្រកាសលេខ ១២១ បទ.ប្រក អនុញ្ញាអោយក្រុមហ៊ុនណុប ផាវង្សខុនស្រ្កាត់សិនចំកាត់ ប្តូរទីតាំងប្រើប្រាស់វិទ្យុទាក់ទង ប្រភេទ VHF ១៨១១

១៨–៩–១៩៩១ – ប្រកាសលេខ ១២២ បទ.ប្រក អនុញ្ញាតអោយក្រុមហ៊ុនកម្ពុជា ស៊ីណាវ៉ាត្រា ផ្អាកឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ១៨១២

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

ព្រះរាជក្រមលេខ ជស/រកម /០៩៩៥/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត ឥសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពី

ការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការឆ្នាំគ្រប់គ្រងឆ្នាំ ១៩៩៥

ភាគទី ១
បទបញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុកែតម្រូវ

ជំពូកទី ១
បទបញ្ញត្តិទូទៅ

មាត្រា ១.‑

មាត្រា ១ មាត្រា ២ មាត្រា ៤ និង មាត្រា ៦ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយ បទបញ្ញត្តិទាំងឡាយ ដូចតទៅ ៖

មាត្រា ១ថ្មី...‑ នៅតែត្រូវបានអនុញ្ញាតសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ អោយប្រមូលជាគុណប្រយោជន៍នៃ ថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន ផលិតផល និងផលទុន ព្រមទាំងការធ្វើអោយសំរេចនូវអំណោយមូលនិធិបរិភាគ និងធនធានបានមកពីការខ្ចីបុល ដែលបានគ្រោងទុកនៅតារាង "ក" ដូចមានបញ្ជាក់នៅភាគទី២ នៃច្បាប់នេះ

មានចំនួនទឹកប្រាក់សរុប..១.២៨៣.០០០ លានរៀល

និងត្រូវបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ .... ៦៩៤.៤០០ លានរៀល
- ចំណូលជាមូលធន .... ៥៨៨.៦០០ លានរៀល

មាត្រា ២ថ្មី.‑ ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទានសំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ត្រូវបានកំណត់ស្មើនឹង .... ១.២៨៣.០០០ លានរៀល
និងត្រូវបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ .... ៧៩២.២០០ លានរៀល
- ចំណាយជាមូលធន .... ៤៩០.៨០០ លានរៀល

មាត្រា ៥ថ្មី.- ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ត្រូវបានកំណត់ស្មើនឹង..............៧៩២.២០០ លានរៀល
ឥណទាននេះត្រូវបានបែងចែកទៅតាមក្រសួងនីមួយៗ និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ និងតាមប្រភេទដូចមានចែងក្នុងតារាង "ខ" ភាគទី ២ នៃច្បាប់ ។

មាត្រា ៦ថ្មី.- ចំនួនទឹកប្រាក់ចំណាយជាមូលធននៃថវិការដ្ឋ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ត្រូវបានកំណត់ស្មើនឹង .... ៤៩០.៨០០ លានរៀល ។ វិនិយោគសាធារណៈដែលរ៉ាប់រងដោយចំណាយជាមូលធន ត្រូវបានបែងចែកតាមប្រភព នៃហិរញ្ញប្បទាន ដូចតទៅ ៖

- វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស...................... ៦៦.៤០០ លានរៀល
- វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស.................. ៣៧២.១០០ លានរៀល

ដោយអនុលោមទៅនឹងបទបញ្ញត្តិនៃមាត្រា ១៥ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការ គ្រប់គ្រងឆ្នាំ ១៩៩៥ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស៩៤ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដូចបានបញ្ជាក់ខាងលើ វិនិយោគដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ គឺជា "ជំនួយគំរោងការ" ។ ចំណូលដែលបានមកពីហិរញ្ញប្បទានផ្ទាល់របស់អ្នកផ្តល់មូលនិធិសំរាប់វិនិយោគសាធារណៈ ឥតឆ្លងកាត់រតនាគារជាតិឡើយ ។ ចំណាយសំរាប់វិនិយោគប្រភេទនេះ មិនរាប់ចូលជាការអនុញ្ញាតចំណាយសំរាប់អាណាប័កទេ ហើយវាមានលក្ខណៈគ្រោងទុកតែនិស្សានតែប៉ុណ្ណោះ ។

ក៏ប៉ុន្តែ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស គឺជាឥណទានថវិកាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាប័ក ដើម្បីសំរេចគំរោងការរបស់ខ្លួន ។ ឥណទាននេះមានលក្ខណៈកំរិតកំណត់ ហើយត្រូវបានគ្រប់គ្រងក្នុងក្របខ័ណ្ឌរតនាគារជាតិ ។

ទាយជ្ជទានសំរាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ និង ឥណទានសំរាប់វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេសនិងសំរាប់ចំណាយជាមូលធនផ្សេងៗទៀត ត្រូវបានបែងចែកតាមក្រសួង តាមស្ថាប័នសាធារណៈប្រហាក់ប្រហែលនិងតាមជំពូកថវិកាដែលមានចែងក្នុងតារាង "ឃ" ដូចបានបញ្ជាក់នៅក្នុងភាគ ទី ២ នៃច្បាប់នេះ ។

មាត្រា ២.-

ត្រូវបានយល់ព្រមការចុះកិច្ចសន្យាខ្ចីបុល ដោយរាជរដ្ឋាភិបាលកម្ពុជា ពីផ្នែកឯកជនក្រៅនិងក្នុងប្រទេស សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៥ ដែលមានទឹកប្រាក់

ចំនួន .... ៣៩៦២៥ លានដុល្លារអាមេរិក

ស្មើនឹង .... ៩៨.៨៨៤ លានរៀល

ប្រភពនៃការខ្ចីបុល	ពាន់ដុល្លារអាមេរិក	លានរៀល
សរុប	៣៩.៦២៥.២	៩៨.៨៨៤.១
ការខ្ចីបុលឯកជនក្រៅប្រទេស	៣៦.៦២៥.២	៩១.១៩៥.១
_ការខ្ចីបុលរយៈពេលមធ្យម៥ឆ្នាំ	៣២.៩៣៧.៨	៨១.៧៤៤.៣
+សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤	១៦.៥២៤.៨	៤២.៣៥៣.១
+សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥	១៦.៤១៣.០	៣៩.៣៩១.២
_ឥណទានអ្នកផ្គត់ផ្គង់២ឆ្នាំ១៩៩៤	៣.៦៨៧.៤	៩.៤៥០.៨
ការខ្ចីបុលឯកជនក្នុងប្រទេស	៣.០០០.០	៧.៦៨៩.០

២ ឆ្នាំ : ១៩៩៥

ហើយត្រូវបែងចែកដូចតទៅ ៖

ទឹកប្រាក់នៃការខ្ចីបុលនេះមានចែងលើតារាង "ក" ដូចបានបញ្ជាក់នៅក្នុងភាគទី ២ នៃច្បាប់ នេះ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ហើយក៏បានដូចគ្នាដែរនៅលើតារាង "ក" នៃច្បាប់ស្តីពីការទូទាត់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ ។ ការបំណុលនៃការខ្ចីបុលនេះ មានចែងលើតារាង "ខ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

ជំពូកទី ២

បទបញ្ញត្តិដែលទាក់ទងនឹងការខ្ចីបុល និង ការធានារបស់រដ្ឋ

ផ្នែកទី ១

ការខ្ចីបុលរបស់រដ្ឋ

មាត្រា ៣.–

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សរ របស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ នៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីបុលជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ។

ក្នុងក្របខ័ណ្ឌនេះ ទឹកប្រាក់ជាអតិបរិមាដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអនុញ្ញាតអោយខ្ចីបុល មានកំរិតរហូតដល់ ១៥០.០០០.០០០ SDR មួយរយហាសិបលានអេសដេអ៊ែ សំរាប់ឆ្នាំ ១៩៩៥ ។

ការខ្ចីបុលដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីបុលសម្បទាន ដែលត្រូវសងវិញ និង ការប្រាក់អនុគ្រោះ ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការទាក់ទងជាមួយធនាគារ_ជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតអោយលក់បណ្ណរតនាគារ ដើម្បីជាកំរៃសំរាប់បំពេញថវិកាជាបណ្តោះអាសន្ន ឬសំរាប់ដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខ័ណ្ឌនៃការលក់បណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់។

ត្រូវហាមឃាត់សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ និងឆ្នាំ ១៩៩៦ នូវការខ្ចីបុល ឬការធានារបស់រដ្ឋតាមលក្ខខ័ណ្ឌពាណិជ្ជកម្ម តែការហាមឃាត់នេះ មិនប៉ះពាល់ដល់បទបញ្ញត្តិ នៃមាត្រា ២ ខាងលើនោះទេ ។

មិនអនុញ្ញាតអោយក្រសួងឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលប័ត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទាន អ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុក ខ្ចីបុល ឬការធានាកិច្ចសន្យាដែល បានចុះហត្ថលេខាយល់ព្រមដោយ

ស្ថាប័នសាធារណៈឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសង បំណុលតាមកាលកំណត់ឬតាមឆ្នាំ ស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌទាំងឡាយដែលច្បាប់នេះកំណត់នោះទេ ។

ល័ក្ខខ័ណ្ឌទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រាល់ការសំរេចលើកិច្ចព្រមព្រៀងស្តីពីការខ្ចីបុល និងការធានារបស់រដ្ឋទៅតាមលក្ខខ័ណ្ឌខាងលើ ត្រូវរាយការណ៍ជូនរដ្ឋសភានាសម័យប្រជុំបន្ទាប់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តបទបញ្ញត្តិទាំងនេះ ជូនរដ្ឋសភារៀងរាល់ ៦ ខែម្តង ។

ផ្នែកទី ២
អំពីការចូលហ៊ុនរបស់រដ្ឋក្នុងសហគ្រាស

មាត្រា ៤.-

ការចូលហ៊ុនរបស់រដ្ឋដោយផ្ទាល់ក្នុងក្រុមហ៊ុនណាមួយ ក្រោមរូបភាពនៃហ៊ុនជាសាច់ប្រាក់ឬជាទ្រព្យសម្បត្តិ អាចធ្វើបានដោយរដ្ឋឬដោយស្ថាប័នសាធារណៈ ក្រោមចំណុះតែក្នុងកំរិតនៃឥណទានដែលត្រូវបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុតែប៉ុណ្ណោះ ។

មាត្រា ៥.-

អនុញ្ញាតអោយរដ្ឋចូលហ៊ុនក្នុងក្រុមហ៊ុនចំរុះ ដែលមានឈ្មោះថា អាកាសចរណ៍ភូមិន្ទកម្ពុជា ដោយមានភាគហ៊ុនជាសាច់ប្រាក់និងជាទ្រព្យសម្បត្តិ ។

ជំពូកទី ៣
អំពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

មាត្រា ៦.-

ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែល

ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង តាមមាត្រា ៣ នៃច្បាប់ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានចាត់ជាកំហុសមួយក្នុងការគ្រប់គ្រងដែលបានប្រព្រឹត្ត ចំពោះរដ្ឋ ៖

_រាល់អំពើដែលបានប្រព្រឹត្តល្មើសនិងបទបញ្ញត្តិដែលបានចែងក្នុងជំពូកទី ២ ខាងលើ

_រាល់អំពើដែលបណ្តាលអោយមានចំណាយលើសឥណទាននៃថវិកាដែលត្រូវបានអនុម័តដោយរដ្ឋសភា លើកលែងតែពីឥណទានដែលត្រៀមទុកសំរាប់បើកផ្តល់ប្រាក់បៀវត្សនិងប្រាក់វិភាជន៍សង្គម ដែលមានការពាក់ព័ន្ធសេវានៃបំណុលនិងការទូទាត់ប្រាក់ដែលយល់ព្រមដោយរដ្ឋសភាព្រមទាំងការបង់វិភាគទាន ចំពោះអង្គការអន្តរជាតិ ។

_រាល់អំពើដែលជាកម្មវត្ថុនាំអោយបង្កើនអោយធនធានពិសេស ទូរទឹកប្រាក់ ឥណទាននៃថវិកាដែលបានទទួលការអនុញ្ញាតពីរដ្ឋសភា លើកលែងតែករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន និង ដោយអនុសញ្ញាអន្តរជាតិដែលរដ្ឋសភាបានអោយសច្ចាប័ន ។

_រាល់កំហុសធ្ងន់ដែលនាំអោយមានការខាតបង់ផលប្រយោជន៍ ដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។

_ ហើយជាទូទៅរាល់សកម្មភាពគ្រប់គ្រងកន្លងមក ដែលជាការប្រព្រឹត្តបទល្មើស និងច្បាប់ និងលិខិតបទដ្ឋានដែលត្រូវអនុវត្តក្នុងការប្រមូលចំណូលនិងក្នុងការទូទាត់ ចំណាយរបស់រដ្ឋ ។

មាត្រា ៧._

អាជ្ញាធរទាំងឡាយដែលមានឋានៈជាអាណាប័កឬអាណាប័កតាមការប្រទានសិទ្ធិ ព្រមទាំងមន្ត្រីរាជការនិងភ្នាក់ការរដ្ឋត្រូវទទួលខុសត្រូវដោយខ្លួនឯងលើការប្រព្រឹត្តបទល្មើស និងបទបញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តថវិកាជូនរដ្ឋសភា រៀងរាល់ ៦ ខែម្តង ដោយយកចិត្តទុកដាក់ខ្ពស់លើល័ក្ខខ័ណ្ឌទាំងឡាយនៃការអនុវត្តទៅតាមបញ្ញត្តិនៃថវិកាព្រមទាំងច្បាប់ ព្រះរាជក្រឹត្យនិងបទបញ្ញត្តិទាំងនោះ ។

ជំពូកទី ៤

បទបញ្ញត្តិស្តីពីពន្ធនិងអាករ

ផ្នែកទី ១

បទបញ្ញត្តិស្តីពីទោសទណ្ឌទាក់ទិននឹងមូលដ្ឋានកំណត់ពន្ធនិងការត្រួតពិនិត្យ

មាត្រា ៨.-

លើកលែងតែពន្ធប្រថាប់ត្រា ពន្ធតែមប្រ៍ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ការមិនបានបង់ ការបង់មិនគ្រប់ ឬការបង់យឺតនូវប្រភេទពន្ធ ឬអាករដែលប្រមូលដោយនាយកដ្ឋានពន្ធដារ ត្រូវបង់បន្ថែមនូវការប្រាក់យឺតយ៉ាវ ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ។

មាត្រា ៩.-

អត្រាការប្រាក់យឺតយ៉ាវមានចំនួន ២% ក្នុងមួយខែ ដោយគិតលើចំនួនទឹកប្រាក់ពន្ធដែលអ្នកជាប់ពន្ធត្រូវបង់បន្ថែមឬលើចំនួនប្រាក់ពន្ធបង់ដោយយឺតយ៉ាវ ។

មាត្រា ១០.-

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ដែលជាខែត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងតាមលក្ខណ្ឌកំណត់ក្នុងមាត្រា២១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ចំណុចផ្តើមនៃការគិត ការប្រាក់យឺតយ៉ាវគឺនៅថ្ងៃទី ០១នៃខែបន្ទាប់ ដែលជាខែផុតរយៈពេលកំណត់សំរាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

មាត្រា ១១.-

ការគិតគូរការប្រាក់យឺតយ៉ាវត្រូវឈប់គិតឬមួយនៅថ្ងៃចុងក្រោយនៃខែដែលបានធ្វើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញឬមួយនៅថ្ងៃចុងក្រោយ នៃខែដែលបានដាក់លិខិតប្រកាសពន្ធ។

មាត្រា ១២._

១_ ក្នុងរយៈពេលកំណត់ ការមិនបានដាក់លិខិតប្រកាសពន្ធ ដែលមានការបញ្ជាក់នូវ ចំណែកទុកសំរាប់កំណត់ឬគណនាប្រាក់ពន្ធឬអាករណាមួយ ដែលប្រមូលដោយនាយកដ្ឋានពន្ធដារនោះ ចំនួនប្រាក់ពន្ធដែលបានមកពីលិខិតប្រកាសពន្ធ ដែលដាក់យឺតយ៉ាវ ត្រូវបូកបន្ថែមលើការប្រាក់យឺតយ៉ាវ ដូចមានចែងក្នុងមាត្រា ៩ ចំនួន ១០% ទៀតនៃចំនួនប្រាក់ពន្ធ ។

២_ ការបន្ថែមចំពោះចំណុច ១ ត្រូវឡើងដល់ :

- ២៥% កាលបើឯកសារបានដាក់ហួសរយៈពេលកំណត់ ១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតរំលឹកដែលបញ្ជាក់ពីកាតព្វកិច្ចត្រូវបំពេញក្នុងរយៈពេលនេះ
- ៥០% ប្រសិនបើពុំបានដាក់ឯកសារណាមួយ ។

មាត្រា ១៣._

ក្នុងករណីដែលលិខិតប្រកាសបង្ហាញអោយឃើញថា មូលដ្ឋានកំណត់ពន្ធ ឬចំណែកសំរាប់គណនាប្រាក់ពន្ធមានលក្ខណៈមិនគ្រប់គ្រាន់ មិនពិតប្រាកដ ឬមិនពេញលេញ ដែលកើតឡើងដោយអចេតនានោះ ចំនួនប្រាក់ពន្ធត្រូវបង់បន្ថែមដោយអ្នកជាប់ពន្ធ ត្រូវបូកបន្ថែមនូវការប្រាក់យឺតយ៉ាវដូចមានចែងក្នុងមាត្រា ៨ និង មាត្រា ៩ ។ ចំនួនប្រាក់បន្ថែមនេះត្រូវឡើងដល់ ៥០% បន្ថែមលើការប្រាក់យឺតយ៉ាវ ប្រសិនបើកំហុសខាងលើនេះត្រូវបានប្រព្រឹត្តដោយចេតនា ។

មាត្រា ១៤._

កាលបើអ្នកជាប់ពន្ធបានបង្ហាញអោយដឹង ដោយការកត់ត្រាយ៉ាងច្បាស់លាស់លើលិខិតប្រកាសពន្ធ លើលិខិតស្នាម ឬលើលិខិតដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយនូវមូលហេតុ ខាងផ្លូវច្បាប់ ឬខាងហេតុការណ៍ដែលអ្នកជាប់ពន្ធមិនបានកត់ត្រានូវចំណែកសំរាប់កំណត់ពន្ធទាំងអស់ ឬចំណែកណាមួយឬក៏បានផ្តល់ចំពោះចំណែកទាំងនេះ នូវការបញ្ជាក់ដែលនាំអោយមានការកំណត់ពន្ធដោយបន្ធូរបន្ថយ ឬការកាត់ កងពន្ធដែលត្រូវបានទទួលស្គាល់ ពេលក្រោយថាមិនសមហេតុផលនោះការកំណត់ពន្ធឡើងវិញចំពោះករណីទាំងនេះ មិននាំអោយមានការអនុវត្តនូវការបង់ការប្រាក់យឺតយ៉ាវដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ ឡើយ ។

មាត្រា ១៥._

ការប្រាក់ពិន័យលើវិធានប្រាក់បន្ថែមមិនត្រូវអនុវត្តទេ កាលបើការខ្វះខាតអំពីពន្ធដែល ប្រកាសពន្ធមិនលើសពី ១ ភាគ ១០ នៃមូលដ្ឋានកំណត់ពន្ធបន្ទាប់ពីមានការកំណត់ពន្ធឡើងវិញ ។

មាត្រា ១៦.-

ត្រូវបានលុបចោលដោយបទបញ្ញត្តិច្បាប់នេះនូវ ៖

- មាត្រា ១៤ នៃអនុក្រឹត្យលេខ ០៧ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩១ ស្តីពី ពន្ធសត្តឃាត
- មាត្រា ២៣ និងមាត្រា ២៤ ជំពូក ៥ នៃក្រឹត្យច្បាប់លេខ ២២ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធដារីតង់
- មាត្រា ១៨ និងមាត្រា ១៩ នៃក្រឹត្យច្បាប់លេខ ២៤ ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធលើទំនិញក្នុងប្រទេស
- មាត្រា ៥៧ មាត្រា ៥៩ និង ចំណុច ១ នៃមាត្រា ៦០ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

ផ្នែកទី ២

បទបញ្ញត្តិស្តីពីការកែប្រែពន្ធលើទំនិញក្នុងប្រទេស ជាអាករពិសេសលើទំនិញមួយចំនួន

មាត្រា ១៧.-

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ ពន្ធលើទំនិញក្នុងប្រទេសដែលបានបង្កើតឡើងដោយក្រឹត្យច្បាប់ លេខ ២៤ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ត្រូវហៅថា "អាករពិសេសលើទំនិញមួយចំនួន" វិញ ដូចមានចែងក្នុងផ្នែកទី ២ ជំពូកទី ៤ នៃ ច្បាប់នេះ ។

មាត្រា ១៨.-

អត្រាអាករពិសេសលើទំនិញមួយចំនួន ដែលពីមុនឡើងដល់ ៥០% នៅតាមក្រឹត្យច្បាប់ដូចយោងខាងលើ ត្រូវបន្ថយអោយមកនៅត្រឹមអត្រាពីរដូចតទៅ ៖

- ២០% សំរាប់គ្រប់ផលិតផលគេលសិលា
- ១០% សំរាប់គ្រប់ផលិតផលផ្សេងទៀត ។

មាត្រា ១៩.-

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួន ទោះបីនាំចូលឬផលិតនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយដូចតទៅ ៖

១- ផលិតផលគេលសិលា :

- ប្រេងសាំងស៊ុបពែរ ឬធម្មតា សំរាប់យានយន្ត

- ប្រេងរំអិល

២- ភេសជ្ជៈ :

- ទឹកមានជាតិឧស្ម័ន មានដាក់ស្ករ ឬក៏សារជាតិផ្អែមផ្សេងទៀត ឬគ្រឿងក្រអូប និង ភេសជ្ជៈដទៃទៀតដែលគ្មានជាតិស្រា លើកលែងតែទឹក និងទឹក មីណេរ៉ាល ហើយនិងទឹកដមផ្លែឈើ ឬ ទឹកដមបន្លែ ។

- ស្រាបៀរ

- ស្រាទំពាំងបាយជូរស្រស់រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិស្រា

- ស្រាវែមុតនិងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិនិងសារជាតិក្រអូប

- ភេសជ្ជៈមៅយផ្សេងទៀត

- អាល់កុលអេទីលីកសុទ្ធដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះពី៨០% នៃចំណុះ ឬ លើសពីនេះ និងអាល់កុលអេទីលីកហើយនិងភេសជ្ជៈមានជាតិស្រាដែលបាត់បង់កំរិតស្រាដើមរបស់វា ។

- អាល់កុលអេទីលីកបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិស្រា ភេសជ្ជៈស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃស្រាផ្សំក្នុងប្រភេទដែលប្រើសំរាប់ផលិតភេសជ្ជៈ ។

៣- បារី បារីស៊ីហ្គា គ្រប់ប្រភេទ ។

មាត្រា ២០.-

ផលិតផលដូចតទៅ លែងត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនទៀតហើយ :

- ថ្នាំជក់មិនកែច្នៃ

- ការ៉េម
- គ្រាប់ឈូក

មាត្រា ២១.-

មូលដ្ឋានកំណត់អាករពិសេសលើទំនិញមួយចំនួន ចំពោះ :

១- ផលិតផលនាំចូល គឺតំលៃក្នុងគយនៃផលិតផលនាំចូលបូកបន្ថែមពន្ធ និងអាករដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសខ្លួនឯងនេះ និង អាករប្រើប្រាស់ដែលត្រូវបង់នាពេលនាំចូល ។

២- ផលិតផលធ្វើនៅព្រះរាជាណាចក្រកម្ពុជា គឺថ្លៃលក់កត់ត្រាក្នុងវិក័យបត្ររបស់អ្នកធ្វើដែលគិតបញ្ចូលទាំងសោហ៊ុយនិងអាករគ្រប់មុខ លើកលែងតែអាករ ពិសេសខ្លួនឯងនេះ និងអាករលើផលរបរ ។

មាត្រា ២២.-

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនដែលបានចែងក្នុងមាត្រា ១៩ ៖

១- ចំពោះទំនិញនាំចូល គឺគ្រប់ការដាក់ទំនិញអោយប្រើប្រាស់នៅលើដែនដីប្រទេសជាតិទៅតាមន័យនៃពាក្យរបស់គយ ។

២- ចំពោះទំនិញផលិតនៅព្រះរាជាណាចក្រកម្ពុជា គឺគ្រប់ការប្រគល់ទំនិញដោយគិតទាំងការប្រគល់ឱ្យដោយឥតយកថ្លៃដែលបានធ្វើឡើងតាមផ្លូវច្បាប់ ឬតាម ហេតុការណ៍ពិតនៅលើដែនដីប្រទេសជាតិ ។

ដោយឡែកត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនផងដែរ នូវទំនិញដែលអ្នកធ្វើ ឬផលិតករកាត់យកសំរាប់តម្រូវការផ្ទាល់ខ្លួន សំរាប់តម្រូវការរបស់បុគ្គលិកឬសំរាប់តម្រូវការរបស់ញាតិយជន ។

មាត្រា ២៣.-

អាករពិសេសលើទំនិញមួយចំនួន ត្រូវបង់ដោយ :

១- អ្នកនាំចូលឬអ្នកកាន់កាប់ទំនិញនៅព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញដែលមានដើមកំណើតពីក្រៅ ។

២- ផលិតករ ឬអ្នកធ្វើ ចំពោះទំនិញផលិត ឬធ្វើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៤.-

អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវកាន់បញ្ជីពិសេសមួយដែលបង្ហាញឱ្យឃើញច្បាស់នូវ ប្រភេទ បរិមាណ គុណភាព តម្លៃ ៖

១_ ចំពោះការនាំចូល និងការបញ្ចូលផលិតផល ទោះបីផលិតផលទាំងនេះ មានដើមកំណើតពីណាក្តី :

- លេខនិងកាលបរិច្ឆេទនៃប្រតិវេទន៍នាំចូល ឈ្មោះការិយាល័យគយដែលយកទំនិញចេញ កាលបរិច្ឆេទទទួល

- បរិមាណទម្ងន់ និងប្រភេទនៃទំនិញនាំចូល

- តម្លៃកត់ត្រាក្នុងវិក័យបត្រនិងមូលដ្ឋានសំរាប់កំណត់អាករពិសេសលើទំនិញមួយចំនួន

- កាលបរិច្ឆេទនិងលេខបង្កាន់ដៃបង់ប្រាក់បញ្ជីពិសេសត្រូវតែមានចុះលេខទំព័រ និងចុះហត្ថលេខាបញ្ជាក់ជាមុនដោយនាយកទីចាត់ការគយ ឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

២_ ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា :

- ស្តុកនៅថ្ងៃទី ៣១ ធ្នូ នៃឆ្នាំនីមួយៗ

- ការកត់ត្រាការធ្វើទំនិញពីមួយថ្ងៃទៅមួយថ្ងៃ

- ការបញ្ចេញទំនិញក៏ត្រូវធ្វើការកត់ត្រាពីមួយថ្ងៃទៅមួយថ្ងៃដែរ ។

បញ្ជីពិសេសត្រូវតែមានចុះលេខទំព័រនិងចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

មាត្រា ២៥._

ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវជូនលិខិតប្រកាសពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី ១០ នៃខែនីមួយៗ អោយទៅផ្នែកពន្ធដារ ដោយមានបញ្ជាក់អំពីមូលដ្ឋានកំណត់អាករ ដែលជាលទ្ធផលនៃប្រតិបត្តិការដែលបានសំរេចក្នុងខែមុន ។

លិខិតប្រកាសត្រូវមានកត់ត្រាបញ្ជាក់អំពីចំនួនប្រាក់អាករពិសេសលើទំនិញមួយចំនួនដែលត្រូវបង់ និងត្រូវបង់ភ្លាមនាឱកាសដាក់លិខិតប្រកាសពន្ធ ។

មាត្រា ២៦._

អាករពិសេសលើទំនិញមួយចំនួន ចំពោះទំនិញនាំចូលត្រូវប្រមូលនាឱកាស

នាំចូលដោយអង្គភាពពន្ធ ក្នុងលក្ខខណ្ឌនិងតាមបទបញ្ញត្តិដូចគ្នានឹងពន្ធគយនិងអាករប្រើប្រាស់ ។

មាត្រា ២៧.-

បុគ្គលទាំងឡាយដែលលក់ផលិតផលស្ថិតក្នុងដែនអនុវត្តន៍នៃអាករពិសេសលើទំនិញមួយចំនួន ត្រូវបង្ហាញភស្តុតាងសំរាប់បញ្ជាក់ថា ផលិតផលដែលដាក់លក់ទាំងនេះពិតជាបានបង់អាករនេះរួចហើយនៅពេលបញ្ចូលក្នុងដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា ។ បើគ្មានភស្តុតាងបញ្ជាក់ទេ ផ្នែកពន្ធដារត្រូវគិតគូរនិងទារប្រាក់អាករដែលត្រូវបង់ និងត្រូវអនុវត្តទោសទណ្ឌជាធរមាន ។

មាត្រា ២៨.-

វិធានច្បាប់ទាំងឡាយស្តីពីអាករលើផលរបរ ដែលប្រមូលនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនផ្ទុយនឹងបទបញ្ញត្តិនៃជំពូកនេះ ត្រូវយកមកអនុវត្តចំពោះអាករពិសេសលើទំនិញផលិតឬធ្វើនៅកម្ពុជា ។

វិធានច្បាប់ទាំងនេះ គឺជាវិធានច្បាប់ចែងអំពីមូលដ្ឋានកំណត់ពន្ធ ការត្រួតពិនិត្យ ទោសបញ្ញត្តិ និងការប្រមូលពន្ធ ។

មាត្រា ២៩.-

១- នីតិវិធីធម្មតានៃការកំណត់ពន្ធឡើងវិញ បន្ទាប់ពីការត្រួតពិនិត្យអាករពិសេសលើទំនិញមួយចំនួន ដែលប្រមូលដោយអង្គការពន្ធ គឺជានីតិវិធីដែលបានចែងនៅមាត្រា ២៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

២- នីតិវិធីនៃការកំណត់ពន្ធជាឯកតោភាគីរបស់អង្គការពន្ធអាចអនុវត្តបានចំពោះករណីទាំងឡាយដូចមានចែងនៅមាត្រា ៥៨ នៃច្បាប់ដូចយោងខាងលើ ។ នីតិវិធីដដែលនេះ អាចអនុវត្តបានក្នុងករណីដែល បញ្ជីពិសេសដូចមានចែងក្នុងចំណុច ២ នៃមាត្រា ២៤ នៃច្បាប់នេះ មិនបានបង្ហាញអោយឃើញ ។

មាត្រា ៣០.-

បទបញ្ញត្តិនៃក្រឹត្យច្បាប់លេខ ២៤ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធលើទំនិញ ក្នុងប្រទេសដែលផ្ទុយនឹងបទបញ្ញត្តិកំណត់ក្នុងផ្នែកនេះ ត្រូវលុបចោលចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។ រាល់ការកែប្រែដែលបានកំណត់ក្នុងផ្នែកនេះ ពុំមានអនុភាព

ប្រតិសកម្មទេ ។

ផ្នែកទី ៣

បទបញ្ញត្តិស្តីពីការកែប្រែការបង់ប្រចាំខែនូវប្រាក់រំដោះពន្ធលើ ប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធតាមរបបពិត

មាត្រា ៣១.-

ចំពោះគ្រប់ប្រតិបត្តិការដែលសំរេចបានគិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៦ ចំនួនប្រាក់រំដោះ ត្រូវបង់ប្រចាំខែសំរាប់ពន្ធលើប្រាក់ចំណេញត្រូវកំណត់ ១% នៃផលរបរគិតរួម បញ្ចូលទាំងអាករគ្រប់ប្រភេទ ដែលសំរេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានផាត់ ចេញពីចំនួនប្រាក់ពន្ធដែលត្រូវបង់នាពេលធ្វើការទូទាត់ប្រាក់ពន្ធជាស្ថាពរ ។

មាត្រា ៣២.-

ទោះបីលទ្ធផលសារពើពន្ធដែលបានធ្វើប្រកាសឬដែលបានទទួលស្គាល់ យ៉ាងណាក៏ ប្រាក់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធ តាមរបបពិតមិនត្រូវតិចជាង ប្រាក់ពន្ធអប្បបរមា ដែលមានចំនួនស្មើនឹង ១% នៃផលរបរ ប្រចាំឆ្នាំ ដោយគិតរួមបញ្ចូលទាំង អាករគ្រប់ប្រភេទផង និងមិនអាចផាត់ចេញពីប្រាក់រំដោះប្រចាំខែ សំរាប់ការិយបរិច្ឆេទ បន្ទាប់ សងវិញឡើយ ។

បទបញ្ញត្តិស្តីពីពន្ធអប្បបរមា ដូចមានចែងនៅក្នុងមាត្រានេះ ត្រូវចាប់អនុវត្តជាលើក ដំបូងសំរាប់ពេលបិទការិយបរិច្ឆេទដែលចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦ ។

ផ្នែកទី ៤

បទបញ្ញត្តិស្តីពីការកំណត់អោយបានស្មើគ្នារវាង អត្រាអាករលើផលរបរ ជាមួយនឹងអត្រាអាករប្រើប្រាស់

មាត្រា ៣៣.-

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ គ្រប់ប្រតិបត្តិការដែលពីមុនជាប់អាករលើ

ផលរបរតាមអត្រា ២% ត្រូវជាប់អាករលើផលរបរតាមអត្រា ៤% ។ ប៉ុន្តែប្រតិបត្តិការទាំងឡាយនៃសកម្មភាពឧស្សាហកម្ម សិប្បកម្មនិងអណ្តូងរ៉ែ ត្រូវជាប់អាករលើផលរបរតាមអត្រា ១% ដដែល ។

ជំពូកទី៥

អវសានបញ្ញត្តិ

មាត្រា ៣៤. _

បទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៥. _

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

ហ៊ុន សែន

II- ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦៧ អនក្រ.បក

ស្តីពី

ការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនកម្ពុជា_ថៃ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ
- បានឃើញសេចក្តីសំរេចលេខ ១៧ សសរ. ចុះថ្ងៃទី ៨ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់កិច្ចសហប្រតិបត្តិការ ខ្មែរ_ថៃ
- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខ ធានាសុវត្ថិភាពនៅតាមព្រំដែនកម្ពុជា_ថៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១: គណៈកម្មការទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ ដែលបានបង្កើតឡើងតាម អនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៩៥ ត្រូវបានហៅថា

"គណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា_ថៃ" ចំណុះការដឹកនាំផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ និងជាសហអគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ហើយត្រូវបានកែសម្រួលសមាសភាព ដូចខាងក្រោម ÷

១_សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាប្រធាន
២_នាយអគ្គសេនាធិការ ជាអនុប្រធាន
៣_នាយរងអគ្គសេនាធិការ ជាសមាជិក
៤_រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក
៥_រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក
៦_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
៧_រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក
៨_អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៩_ឯកអគ្គរាជទូតកម្ពុជា ប្រចាំក្រុងបាងកក ជាសមាជិក
១០_មេបញ្ជាការកងនាវាចរខេមរភូមិន្ទ ជាសមាជិក
១១_មេបញ្ជាការកងអាកាសចរខេមរភូមិន្ទ ជាសមាជិក
១២_នាយកទីចាត់ការគលយុទ្ធ អគ្គបញ្ជាការដ្ឋាន ជាសមាជិក
១៣_នាយកខុទ្ទកាល័យយោធាក្រសួងការពារជាតិ ជាសមាជិក
១៤_នាយកខុទ្ទកាល័យស៊ីវិលក្រសួងការពារជាតិ ជាសមាជិក
១៥_នាយកនាយកដ្ឋានឃោសនាសាធារណៈក្រសួងការពារជាតិ ជាសមាជិក
១៦_មេបញ្ជាការកងការពារព្រំដែន ជាសមាជិក និងលេខាធិការ
១៧_នាយកនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសក្រសួងពាណិជ្ជកម្ម ជាសមាជិកនិងលេខាធិការរង

មាត្រា ២ : បង្កើតគណៈកម្មាធិការ រក្សាសន្តិភាពព្រំដែនទូទៅ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃដែល រួមមានសមាសភាពដូចខាងក្រោម ÷

១_នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ជាប្រធាន
២_នាយរងអគ្គសេនាធិការ ជាអនុប្រធាន
៣_រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាអនុប្រធាន
៤_អនុរដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៥_អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

៦_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧_តំណាងអាជ្ញាធរជាតិកម្ពុជា ទទួលបន្ទុកការងារព្រំដែន ជាសមាជិក

៨_ឯកអគ្គរាជទូតកម្ពុជា ប្រចាំក្រុងបាងកក ជាសមាជិក

៩_អគ្គនាយករងនគរបាលជាតិ ជាសមាជិក

១០_នាយក នាយកដ្ឋានស្រាវជ្រាវ និង ចារកិច្ច អគ្គបញ្ជាការដ្ឋាន ជាសមាជិក

១១_មេបញ្ជាការកងការពារព្រំដែន ជាសមាជិក

១២_មេបញ្ជាការរង កងនាវាចរខេមរភូមិន្ទ ជាសមាជិក

១៣_មេបញ្ជាការរង កងអាកាសចរខេមរភូមិន្ទ ជាសមាជិក

១៤_នាយការិយាល័យទី ៣ អគ្គសេនាធិការ ជាសមាជិក

១៥_នាយក ទីចាត់ការគយ និង រដ្ឋាករ ជាសមាជិក

១៦_ប្រធាននាយកដ្ឋាន រុក្ខា-ប្រមាញ់ ជាសមាជិក

១៧_ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ក្រសួងមហាផ្ទៃ ជាសមាជិក

១៨_នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ ជាសមាជិក

១៩_ប្រធានការិយាល័យប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ជាសមាជិក

២០_មេបញ្ជាការរងកងការពារព្រំដែន ជាសមាជិកនិងលេខាធិការ

២១_នាយការិយាល័យទី ៣ កងនាវាចរខេមរភូមិន្ទ ជាសមាជិកនិងលេខាធិការរង

មាត្រា ៣ : បង្កើតគណៈកម្មាធិការថ្នាក់យោធភូមិភាគ សំរាប់ដោះស្រាយការងារតាមមូលដ្ឋានរបស់ខ្លួន ដែលរួមមានសមាសភាពដូចខាងក្រោម ÷

យោធភូមិភាគទី ៤

១_មេបញ្ជាការយោធភូមិភាគ ៤ ជាប្រធាន

២_មេបញ្ជាការរងយោធភូមិភាគ ៤ ជាអនុប្រធាន

៣_អភិបាលខេត្ត ព្រះវិហារ ជាអនុប្រធាន

៤_អភិបាលខេត្ត ឧត្តរមានជ័យ ជាអនុប្រធាន

៥_អភិបាលខេត្ត សៀមរាប ជាអនុប្រធាន

៦_មេបញ្ជាការកងពលធំលេខ ៣ ជាសមាជិក

៧_មេបញ្ជាការកងពលធំលេខ ១៤ ជាសមាជិក

៨_តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៩_នគរបាលអន្តោប្រវេសន៍ខេត្តព្រះវិហារ,ឧត្តរមានជ័យ,សៀមរាប ជាសមាជិក
១០_ទីស្នាក់ការគយនិងរដ្ឋាករ ខេត្តព្រះវិហារ,ឧត្តរមានជ័យ,សៀមរាប ជាសមាជិក
១១_ចៅក្រសួងពាណិជ្ជកម្មខេត្តព្រះវិហារ, ឧត្តរមានជ័យ, សៀមរាប ជាសមាជិក
១២_ចៅក្រសួងកសិកម្ម ខេត្តព្រះវិហារ , ឧត្តរមានជ័យ , សៀមរាប ជាសមាជិក
១៣_នាយសេនាធិការ យោធភូមិភាគទី ៤ ជាសមាជិកនិងលេខាធិការ
១៤_នាយសេនាធិការកងពលធំលេខ ៣ ជាសមាជិកនិងលេខាធិការរង
១៥_នាយសេនាធិការកងពលធំលេខ ១៤ ជាសមាជិកនិងលេខាធិការរង

យោធភូមិភាគទី ៥

១_មេបញ្ជាការយោធភូមិភាគទី ៥ ជាប្រធាន
២_មេបញ្ជាការរងយោធភូមិភាគទី ៥ ជាអនុប្រធាន
៣_អភិបាលខេត្តបន្ទាយមានជ័យ ជាអនុប្រធាន
៤_អភិបាលខេត្តបាត់ដំបង ជាអនុប្រធាន
៥_មេបញ្ជាការកងពលធំលេខ ១២ ជាសមាជិក
៦_មេបញ្ជាការកងពលធំលេខ ៧ ជាសមាជិក
៧_នគរបាលអន្តោប្រវេសន៍ ខេត្តបន្ទាយមានជ័យ, បាត់ដំបង ជាសមាជិក
៨_តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៩_ចៅក្រសួងពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១០_ចៅក្រសួងកសិកម្ម ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១១_ទីស្នាក់ការ គយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១២_នាយសេនាធិការ យោធភូមិភាគទី ៥ ជាសមាជិកនិងលេខាធិការ
១៣_នាយសេនាធិការ កងពលធំលេខ ១២ ជាសមាជិកនិងលេខាធិការរង
១៤_នាយសេនាធិការ កងពលធំលេខ ៧ ជាសមាជិកនិងលេខាធិការរង

យោធភូមិភាគទី ៣

១_មេបញ្ជាការយោធភូមិភាគទី ៣ ជាប្រធាន
២_មេបញ្ជាការរងយោធភូមិភាគទី ៣ ជាអនុប្រធាន
៣_អភិបាលខេត្តកោះកុង ជាអនុប្រធាន

៤_មេបញ្ជាការកងនាវាចរខេមរភូមិន្ទ (មូលដ្ឋានសមុទ្រ) ជាអនុប្រធាន

៥_មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ខេត្តកោះកុង ជាអនុប្រធាន

៦_តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៧_ទីស្នាក់ការគយ និង រដ្ឋាករ ខេត្តកោះកុង ជាសមាជិក

៨_ចៅក្រសួងពាណិជ្ជកម្ម ខេត្តកោះកុង ជាសមាជិក

៩_ចៅក្រសួងកសិកម្ម ខេត្តកោះកុង ជាសមាជិក

១០_នគរបាលអន្តោប្រវេសន៍ ខេត្តកោះកុង ជាសមាជិក

១១_មេបញ្ជាការកងវរសេនាតូច ការពារព្រំដែនខេត្តកោះកុង ជាសមាជិក

១២_មេបញ្ជាការកងវរសេនាតូច នាវាចរល្បាតព្រំដែនសមុទ្រ ជាសមាជិក

១៣_នាយសេនាធិការយោធភូមិភាគទី ៣ ជាសមាជិក

១៤_នាយការិយាល័យទី ៣ យោធភូមិភាគទី ៣ ជាសមាជិក និង លេខាធិការ

១៥_នាយសេនាធិការកងនាវាចរមូលដ្ឋានសមុទ្រ ជាសមាជិក និងលេខាធិការរង

១៦_មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង

ជាសមាជិកនិងលេខាធិការរង

មាត្រា ៤ : ដើម្បីជាជំនួយដល់គណៈកម្មាធិការនេះ ក្នុងការសហការដោះស្រាយការងារអោយបានល្អ ទៅតាមភូមិសាស្ត្រនីមួយៗ ចាំបាច់ត្រូវរៀបចំការិយាល័យ និងក្រុមការងារមួយចំនួនប្រចាំតាមបណ្តាទិសនៃយោធភូមិភាគនីមួយៗ ។ ចំពោះសមាសភាព និងភារកិច្ចរបស់ការិយាល័យ និងក្រុមការងារនីមួយៗ អាស្រ័យដោយគណៈកម្មាធិការព្រំដែនទូទៅ និង គណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅជាអ្នករៀបចំ និងកំណត់ជាក់ស្តែង ។

មាត្រា៥ : គណៈកម្មាធិការនេះ មានភារកិច្ចរិះរកវិធានការដឹកនាំដ៏សមស្របដើម្បីលើកស្ទួយសហប្រតិបត្តិការ រក្សាសន្តិភាពតាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរកម្ពុជា–ថៃ ។ ចេញបទបញ្ជា គោលនយោបាយ និង ផែនការអោយគណៈកម្មាធិការភូមិភាគ ការិយាល័យ និង ក្រុមការងារ ដើម្បីអនុវត្តអោយបានល្អប្រសើរនូវរាល់ទំនាក់ទំនងនេះ ។ ចាត់តាំងគណៈកម្មាធិការឯកទេស ដើម្បីដោះស្រាយរាល់ករណីដែលកើតក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីមួយៗ ។

មាត្រា ៦ : ទីកន្លែងធ្វើការរបស់គណៈកម្មាធិការព្រំដែនទូទៅនៅក្រសួងការពារជាតិ ។ ចំណែកឯគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ ធ្វើការនៅទីបញ្ជាការដ្ឋានកងការពារព្រំដែនអគ្គសេនាធិការ ។

មាត្រា ៧ : គណៈកម្មាធិការព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។ ចំពោះគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

មាត្រា ៨ : ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ ស្ថាប័នពាក់ព័ន្ធនិងសមាសភាពស្ថិតនៅក្នុង មាត្រា ១ , មាត្រា ២ , មាត្រា ៣ , ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ១០: អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៦៨ អនក្រ.បក

ស្តីពីការបង្កើតមន្ទីរប្រូនាំងគ្រឿងញៀន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន**

ព្រះមហាក្សត្រ · នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

សំរេច

មាត្រា ១ : បង្កើតមន្ទីរប្រឆាំងគ្រឿងញៀន ។

មន្ទីរប្រឆាំងគ្រឿងញៀនមានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយស្ថិតនៅក្រោមឱវាទអគ្គ-នាយកដ្ឋាននគរបាលជាតិ ។

មាត្រា ២ : មន្ទីរប្រឆាំងគ្រឿងញៀនមានភារកិច្ចដូចតទៅ ÷

- ដឹកនាំ និង បញ្ជាកម្លាំងនគរបាលស្រាវជ្រាវពត៌មាន និង ចាត់វិធានការទប់ស្កាត់ និង បង្ក្រាបគ្រឿងញៀន ។
- សហការជាមួយនាយកដ្ឋាន និង ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ផ្តល់ពត៌មានដែលទាក់ទងនឹងគ្រឿងញៀន មកមន្ទីរប្រឆាំងគ្រឿងញៀន ដើម្បីចាត់វិធានការបង្ក្រាប ។
- ទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងសុខា-ភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គយ) ក្រសួងការពារជាតិ (កងរាជអាវុធហត្ថ) ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងការបរទេស និង

សហប្រតិបត្តិការអន្តរជាតិ សមាគម និងស្ថាប័នផ្សេង ៗ ដើម្បីសហការប្រឆាំងនឹងគ្រឿងញៀន ។

- រៀបចំផែនការប្រឆាំងគ្រឿងញៀនស្របតាមគោលការណ៍អន្តរជាតិ និង តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់បង្ក្រាបគ្រឿងញៀន ។
- ចូលរួមប្រជុំ ស្ដីអំពីការបង្ក្រាបគ្រឿងញៀននៅក្នុងប្រទេស និង ក្រៅប្រទេស ។
- រៀបចំកម្មវិធីហ្វឹកហ្វឺនកងកម្លាំងនគរបាលជាតិ អំពីការទប់ស្កាត់ និង បង្ក្រាបគ្រឿងញៀន ។
- អនុវត្តភារកិច្ចផ្សេង ៗ ទៀតពាក់ព័ន្ធនឹងគ្រឿងញៀន ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនប្រគល់អោយ ។

មាត្រា ៣ : ការរៀបចំជាក់ស្ដែងនូវភារកិច្ច និង របនាសម្ព័ន្ធរបស់មន្ទីរប្រឆាំងគ្រឿងញៀន ត្រូវកំណត់ដោយប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៦៩ អនក្រ.បក

ស្ដីពីការបង្កើតសាលាកសិកម្មកំពង់ចាម

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាម ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : បង្កើតសាលាកសិកម្មនៅ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ដែលមានឈ្មោះថា សាលាកសិកម្មកំពង់ចាម (សកកច) ដែលស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : សាលាកសិកម្មកំពង់ចាម មានភារកិច្ចដូចតទៅ ÷

-បណ្តុះបណ្តាល និងសុក្រឹត្យការអ្នកបច្ចេកទេសកំរិតមធ្យម បឋម និង បំពាក់បំប៉នហ្វឹកហ្វឺនវគ្គខ្លី ។ តាមមុខវិជ្ជាឯកទេសកសិកម្មក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

-ចាត់តាំងអោយមានការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស និង ការងារផលិតកម្មលើវិស័យកសិកម្ម ។

-ស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀនអោយបានសមស្របទៅតាមលក្ខណៈទឹកដី នៃប្រទេសជាតិ ។

-បណ្តុះបណ្តាល និងសុក្រឹត្យការទៅតាមសេចក្តីត្រូវការ ទាំងគុរកោសល្យ និងជំនាញ ។

-កសាងគំរោងផែនការអភិវឌ្ឍន៍សាលាកសិកម្មកំពង់ចាម អោយបានសមស្របទៅតាមការរីកចំរើនរបស់សង្គមកម្ពុជា ។

មាត្រា ៣ : សាលាកសិកម្មកំពង់ចាម មានថ្នាក់ស្មើនឹងមន្ទីរជំនាញនៅតាមខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជានិងមាននាយកម្នាក់រូបទទួលខុសត្រូវរួម និងនាយករងជាជំនួយការ ។

មាត្រា ៤ : សាលាកសិកម្មនេះ ទទួលបន្ទុកបណ្តុះបណ្តាលជាដំបូងលើមុខជំនាញ ៣ គឺ ÷

១-ក្សេត្រសាស្ត្រ

២–ផលិតកម្ម និង បសុព្យាបាល

៣–ដំណាំកៅស៊ូ

ផ្អែកលើការរីកចំរើន នៃខឿនសេដ្ឋកិច្ចជាតិ និង សមត្ថភាពរបស់សាលាកសិកម្មនេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អាចបើកបណ្ដុះបណ្ដាលនូវមុខជំនាញចាំបាច់ផ្សេង ៗ ទៀត ដែលពាក់ព័ន្ធលើវិស័យកសិកម្មក្រៅពីមុខជំនាញដែលរៀបរាប់ខាងលើ ។

មាត្រា ៥ : ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់សាលាកសិកម្មកំពង់ចាម ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ ក្របខ័ណ្ឌមន្ត្រីរាជការរបស់សាលានេះ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអ្នកកំណត់អោយប្រើប្រាស់ ។

មាត្រា ៦ : សាលាកសិកម្មកំពង់ចាម ស្ថិតនៅលើដីដែលជាកម្មសិទ្ធិ នៃអតីតសាលាបណ្ដុះបណ្ដាល វិជ្ជាជីវៈមិត្តភាពកម្ពុជា–ហុងគ្រី ។ ខេត្តកំពង់ចាម ត្រូវសិ្ររួលផ្ដល់ដីនេះដល់សាលាកសិកម្ម កំពង់ចាម ។

មាត្រា ៧ : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមកពាក់ព័ន្ធ និង សាលាកសិកម្មកំពង់ចាម ហើយផ្ទុយ ពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ស្ថាប័នមានការការពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៩ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១០៥ អនក្រ.តត

ស្តីពីការជូនដោយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សាលាក្រុងភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះលោក **ស្រី សាធារណ៍** ដែលមានចិត្តសប្បុរសធម៌ចំណាយប្រាក់ ចំនួន ៤១.៤២៥ ដុល្លារអាមេរិក ជួយធ្វើផ្លូវពីរោងចក្រអគ្គិសនីទី ៤ ដល់ វត្តញាណរង្សី ប្រវែង ១.២០០ ម៉ែត្រ ទទឹង ១០ ម៉ែត្រ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១០៦ អនក្រ.

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ព្រះចៅអធិការវត្តមន្ត្រីភិមុខតេជោ ហៅវត្តជ្រោយ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះពុទ្ធបរិស័ទ្ធជាសប្បុរសជន ដែលមានសទ្ធាជ្រះថ្លាជួយកសាងព្រះវិហារវត្តមន្ត្រីភិមុខតេជោ ហៅវត្តជ្រោយ នៅឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង សប្បុរសជនទាំងអស់មាន ០៦ រូប ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឧបាសិកា **ឯម ពាញ** ព្រមទាំងបុត្រ ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក
២-អ្នកស្រី **លឹម សំបូរ** និង ស្វាមី ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក
៣-អ្នកស្រី **អ៊ីវ សុធា** និង ស្វាមី ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក
៤-លោក **ទ័ម៉ន សារុន** និងភរិយា ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក
៥-លោកឧកញ៉ា **សុខ គង់** និងភរិយា ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក
៦-លោក **ខឌ្យូ ពិសេន** និងភរិយា ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទីឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១០៧ អនក្រ.តត

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **ឈឹម ប្រាជ** ទីប្រឹក្សាស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសហព័ន្ធរុស្ស៊ីអោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយត្រូវចប់អាណត្តិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការ

ដ្ឋានមុខងារសាធារណៈ និងលោក **ឈឹម ឡាន** ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះ ហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១០៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីជាកុងស៊ុលព្រះរាជាណាចក្រ

កម្ពុជា ប្រចាំទីក្រុងហុងកុង

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោក **ឈឹម អេងឡេ** ជាកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហុងកុង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការ

ជូនមុខងារសាធារណៈ និងលោក លឹម អេង្សេង ត្រូវអនុវត្តអនុក្រឹត្យនេះ ដែល ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ត លេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

សារាចរលេខ ០៦ សរ

ស្តីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងគម្រប់ព្រះជន្ម ៧៣ យាងចូល ៧៤ ព្រះវស្សា បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក និង បុណ្យខួបអនុស្សាវរីយ៍លើក ទី ៤២ នៃទិវាបុណ្យឯករាជ្យ ជាតិ ៩ វិច្ឆិកា

* * *

* ពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈ ក្នុងគម្រប់ព្រះជន្ម ៧៣ យាងចូល ៧៤ ព្រះវស្សានឹងត្រូវ ប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ ចាប់ពីថ្ងៃទី ៣០–៣១ តុលា ដល់ ០១ វិច្ឆិកា ១៩៩៥ ខាងមុខនេះ ដើម្បី សំដែងកតញ្ញូតាធម៌ចំពោះព្រះមហាករុណាធិគុណ ថ្វាយព្រះពរសព្ទសាធុការ និងថ្វាយមហាកុសល ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ នៅជាម្លប់ដ៏ត្រជាក់របស់ប្រជារាស្ត្រ ខ្មែរយូរអង្វែងតរៀងទៅ ។

* ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និង អកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ គឺថ្ងៃទី ៦–៧–៨ ខែ វិច្ឆិកា ១៩៩៥ ដើម្បីបើកឱកាសជូនប្រជារាស្ត្រ សប្បាយរីករាយ ចូលរួម

ថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធ នៃកំលាំងសាមគ្គីកងទ័ពជើងទឹករបស់យើង ដើម្បីការពារមាតុភូមិ និងសំដែងមនោសញ្ចេតនា ប្រកបដោយកតញ្ញូតាធម៌ចំពោះមហាករុណាទិគុណ នៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុសក្តិសិទ្ធដែលបានគាំពារ និងជួយឧបត្ថម្ភអោយវិស័យកសិកម្ម ជាតិមានការចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួងអោយបារមី នៃព្រះពុទ្ធជាអម្ចាស់និងវត្ថុសក្តិសិទ្ធិទាំងនោះ បន្តជួយឧបត្ថម្ភវិស័យ កសិកម្ម នាផ្លូវខាងមុខអោយទទួលបានជោគជ័យ និងទិន្នផល ខ្ពស់ជាងនេះថែមទៀត ។

* ពិធីបុណ្យអនុស្សាវរីយ៍លើកទី ៤២ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដើម្បីសំដែងមនោសញ្ចេតនាអុបអរសាទរ រំលឹកទិវាជាប្រវត្តិសាស្ត្រដែលកំលាំង មហាសាមគ្គីជាតិទាំងមូល ដណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំងនាឆ្នាំ ១៩៥៣ នូវ ឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លា នៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងបី ខាងលើនេះអោយបានសមរម្យ សក្តិសមទៅនឹងព្រះមហាករុណា ទិគុណ និងព្រហ្មវិហារដ៏ខ្ពស់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសក្តិសមទៅនឹងភោគផល សម្បត្តិធម្មជាតិប្រពៃណី ទំនៀមទម្លាប់ ដ៏រុងរឿងរបស់ជាតិ និងអត្ថន័យដ៏ជ្រាលជ្រៅ នៃទិវាបុណ្យ ឯករាជ្យជាតិ ដែលជាសមិទ្ធផលនៃកំលាំងរួបរួមដ៏ពិសិដ្ឋរបស់ប្រជាជាតិយើងយបានម្តេជ្ជាចិត្ត យ៉ាងក្លៀវក្លាដណ្តើមយកមកវិញនូវអ្វីៗដែលជារបស់ទ្រព្យ ជាកម្មសិទ្ធិ និងជាសិទ្ធិនៃមាតុភូមិកម្ពុជាយើង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ ÷

១–ពិធីបុណ្យចំរើនព្រះជន្ម :

–គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិអន្តរជាតិ សហការជាមួយអគ្គនាយកដ្ឋានព្រះបរមរាជវាំង ត្រូវចាត់តាំងពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៅក្នុងព្រះបរមរាជវាំងអោយ បានឧឡារិក អធិកអធម ស្របតាមប្រពៃណីជាតិ និងប្រពៃណីសាសនា ដោយមានថ្នាក់ដឹកនាំ ព្រះរាជវង្សានុវង្ស មន្ត្រីរាជការ អ្នកមុខអ្នកការ គ្រប់ជំណែង គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត–ក្រុង ចូលរួមថ្វាយព្រះពរ ។

–គ្រប់ ខេត្ត–ក្រុង ត្រូវចាត់តាំងពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាអម្ចាស់ជីវិតលើត្បូងក្នុងក្របខ័ណ្ឌ ខេត្ត–ក្រុង របស់ខ្លួនអោយបានឧឡារិក ដោយមានមន្ត្រីរាជការថ្នាក់ដឹកនាំខេត្ត–ក្រុងមន្ទីរនានា ជុំវិញ ខេត្ត–ក្រុង ខ័ណ្ឌ ស្រុក អ្នកមុខអ្នកការ និងប្រជារាស្ត្រចូលរួមថ្វាយព្រះពរ ។

–គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត–ក្រុង ត្រូវរៀបចំតាំងព្រះឆាយាលក្ខណ៍ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង តុបតែងអំពូល រចនាដោយភ្លើង ពណ៌ និង ពាក្យស្លោកថ្វាយព្រះពរ ព្រមទាំងសារលិខិតថ្វាយព្រះពរ ។ នៅពេលយប់មានចាត់តាំងក្រុមតន្ត្រីសិល្បៈបូរាណ សម័យ សំដែងជូនប្រជារាស្ត្រ ទស្សនាកំសាន្តសប្បាយទៅតាមទីធ្លាសាធារណៈ ។

២–អំពីពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក :

–គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ–អន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ និង ខេត្ត–ក្រុង ចាត់តាំងរៀបចំពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមផងទន្លេសាប នៅវេទិកាអុំទូក មុខព្រះបរមរាជវាំង ក្នុងរយៈកាល ៣ ថ្ងៃ តាមប្រពៃណីជាតិ ប្រពៃណីសាសនា ដោយ មានចាត់តាំងក្រសួងមួយចំនួន រចនាតុបតែងជាប្រទីប មានអុចកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌ រន្ទាលច្រាលផ្លៅនៅរាជធានីភ្នំពេញ ។

–គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ–អន្តរជាតិ ត្រូវមានការលើ[illegible]ស្តែង ស្តីពីលក្ខខ័ណ្ឌទាំងឡាយ នៃការជ្រើសរើសទូក ខ ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ–ទូកចែវ អោយបាន ច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវសប្បុរសជន បណ្តាក្រុមហ៊ុនឯកជន អោយជួយឧបត្ថម្ភជា សំភារៈ ថវិកាសំរាប់ជូនរង្វាន់ដល់កីឡាករអុំទូក ។

–ខេត្ត–ក្រុង ដែលមានទូក ង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បង ចម្រាញ់ជ្រើសរើសទូកដែលមានចំណាត់ថ្នាក់ ជាទូកលឿនរបស់ខេត្ត–ក្រុងក្នុងចំនួនតិចបំផុត សម្រាប់ចូលរួមប្រណាំងនៅរាជធានី ភ្នំពេញ ។

៣–អំពីពិធីបុណ្យឯករាជ្យជាតិ :

–ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤២ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងកំរិតមួយ ដ៏សមស្រប សក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងពិធីអុជទៀនជ័យ ដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ និងពន្លត់ទៀនជ័យទើបមានឯករាជ្យ ព្រមទាំង[illegible] បង្ហោះប៉េងប៉ោង លែងព្រាបជា និមិត្តរូបនៃការសុំសុខសន្តិភាពផង ។

–ខេត្ត–ក្រុង ត្រូវចាត់តាំងពិធីគោរពវិញ្ញាណក្ខន្ធនៅតាមទីកន្លែងដ៏សមគួរ តាមការជាក់ស្តែងរបស់ខេត្ត ក្រុងនីមួយៗ ។

–គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ–អន្តរជាតិ ត្រូវរៀបចំកម្មវិធីសំរាប់ថ្នាក់ដឹកនាំក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចុះសួរសុខទុក្ខកងយោធពលខេមរភូមិន្ទ នៅសមរភូមិ របួសកំពុងសម្រាក ព្យាបាលនៅតាមមន្ទីរពេទ្យ មណ្ឌលយុទ្ធជនពិការ ដោយមានទាំអំណោយជួយឧបត្ថម្ភ និងបំផុសអោយ គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័ន បងបដា ពាក្យស្លោក ដោតទង់ជាតិ ទង់ក្លែប និង តុបតែង លំអភ្លើងពណ៌អោយបានឧឡារិក ។

–ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងរៀបចំកម្មវិធីសិល្បៈ និងចម្រៀងសម័យបុរាណ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តនៅតាមទីសាធារណៈ អបអរសាទរ ក្នុងពិធីបុណ្យទាំង ៤ ខាង លើ ។ ខេត្ត ក្រុង ក៏ត្រូវមានចាត់តាំងសិល្បៈសំដែងជូនប្រជារាស្ត្រទស្សនាកំសាន្ត ដូចនៅរាជធានីភ្នំ ពេញដែរ ។

–ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសំភារៈ និង ថវិកាសំរាប់បំរើការរៀបចំពិធីបុណ្យទាំង ៤ ខាងលើអោយបានសមស្រប និង ទាន់ពេលវេលា ។

–គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ–អន្តរជាតិ ត្រូវបូកសរុបគំរោងថវិកាចំណាយលំអិតដែល ក្រសួងពាក់ព័ន្ធបានលើកឡើង ក្នុងស្មារតីសន្សំសំចៃ ប្រែប្រសិទ្ធិភាពខ្ពស់ ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច ។

ទទួលបានសារាចរនេះ សូមឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត–ក្រុង ចាត់តាំងអនុវត្តអោយបានសំរេចលទ្ធផល ល្អប្រសើរស្របតាមគោលបំណង និងសំណូមពរ ហើយធ្វើរបាយការណ៍បូកសរុបជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

ជ.រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

ពាក្យស្លោកសំរាប់ប្រើប្រាស់

ធ្វើបដា និងបង់កាត ក្នុងពិធីបុណ្យទាំង ៤ បុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន បុណ្យតាំងតួ បុណ្យខួបឯករាជ្យជាតិ បុណ្យអុំទូក បណ្តែតប្រទីបសំពះព្រះខែ និង អកអំបុក

* * *

១–សូមថ្វាយព្រះពរព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃកម្ពុជា មានព្រះសុខ មាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២–សូមថ្វាយព្រះពរសម្តេចឪ សម្តេចម៉ែ ជាទីគោរពសក្ការៈ ។

៣–សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៤–ជយោ សម្តេចឪ និងសម្តេចម៉ែ

៥–អបអរសាទរយ៉ាងគ្រឿកគ្រេងខួបអនុស្សាវរីយ៍លើកទី៤២ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា «០៩–១១– ៥៣ ដល់ ០៩–១១–៩៥ » ។

៦–ចងចាំជានិច្ច នូវ ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តម របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ។

៧–ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ជាព្រះអគ្គមគ្គុទេសក៍ដ៏ឆ្នើមតែមួយគត់ របស់ប្រជារាស្ត្រខ្មែរ ។

៨–ជយោ : លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា

៩–ជយោ : សន្តិភាព និងការបង្រួបបង្រួមជាតិ

១០–ជយោ : ព្រះរាជាណាចក្រកម្ពុជា

១១–ជាតិ សាសនា ព្រះមហាក្សត្រ

១២–អបអរសាទរទិវាបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក

១៣–អបអរសាទរ លទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

១៤–យុទ្ធសាស្ត្រចុងក្រោយរបស់រាជរដ្ឋាភិបាល «គឺធ្វើយ៉ាងណាអោយរាស្ត្រមានមុខរបរ

១៥–ជយោ : សន្តិភាព និងការអភិវឌ្ឍន៍

១៦–ជយោ : សម្តេចព្រះបិតាឯករាជ្យជាតិ

១៧–ជយោ : សម្តេចព្រះបិតាសន្តិភាពផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ

III- ការងាររបស់ក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៧១៩ ឧក.ប្រក ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ១ : អនុញ្ញាតអោយលោក **ទឹម តឹក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩០០៦៥ ក.ណ ចុះថ្ងៃទី ០២-៥-៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិ ឡុកដូ ឃុំ ព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាលបន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **ទឹម តឹក** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត៦៥ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវផ្ញើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧២០ ឧក.ប្រកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ហោ ហាក់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៥០៤៧ ក.ស្ព ចុះថ្ងៃទី ២៤-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៣ ភូមិចំបក់ ឃុំរលួស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ហោ ហាក់** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧២១ ឧក.ប្រក ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ថាយ សេងឡេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១១៣៤៦៤ ក.ប ចុះថ្ងៃទី ២៤-៩-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែរការ ឃុំ ធកឈើខាងស្រុក អង្គស្នួល ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ថាយ សេងឡេង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ: ៧២២ ឧក.ប្រក ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១: អនុញ្ញាតអោយលោក **ទ៉េង ឆាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២០១៣៥៣ ក.ណ ចុះថ្ងៃទី ១៧-១០-៨៨ អាស័យដ្ឋានបច្ចុប្បន្នភូមិល្វាសក្រោម ឃុំល្វាស ស្រុកល្វាឯម ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ ៤០សេះ នៅក្នុងទីតាំងភូមិ ល្វាយក្រោម ឃុំល្វាស ស្រុកល្វាឯម ខេត្តកណ្តាល។

ប្រការ ២ : លោក **ទ៉េង ឆាយ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ: ៧២៣ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ខាម ខឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៨៩៩៨ ក.ណ. ចុះថ្ងៃទី ០២_០១_១៩៨៥ អាស័យដ្ឋានបច្ចុប្បន្នភូមិស្រីស្នំ ឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ លោក **ខាម ខឹម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងឡើយ ។

ប្រកាសលេខ: ៧២៤ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ុត ខុម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៣៦៨៤ ក.ឆ ចុះថ្ងៃទី ១៨_១០_១៩៨២ អាស័យដ្ឋានបច្ចុប្បន្នភូមិត្រពាំងបី ឃុំលេខ ១ ទីរួមខេត្តកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បើកដំណើរការផលិតកម្មទឹកកកដើមនៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវ ដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាស លេខៈ ៧២៥ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុំ ឥុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៨៦៨៩ ភ.ព ចុះថ្ងៃទី ១១_៩_១៩៩០ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៨ សេអ៊ីព ផ្លូវ លេខ ១០៥ សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតទឹកក្បុង « រូបដីរ » នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក អ៊ុំ ឥុង ត្រូវផលិតនូវផលិតផលទឹកក្បុង « រូបដីរ » ស្របតាមគំរូផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណាងឡើយ ។

ប្រកាស លេខៈ ៧២៦ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ហុង គីមស្រ៊ុន** ជនជាតិខ្មែរសញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៤៤០៥ ក.ឆ ចុះថ្ងៃទី ២១_៨_១៩៩០ អាស័យដ្ឋានបច្ចុប្បន្នភូមិផ្សារឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បើកដំណើរការឡឥដ្ឋក្បឿង នៅក្នុងទីតាំង ភូមិចុងកោះ ឃុំផ្សារឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណាងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

ភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ: ២៣៧/៩៥ ពម.ប្រក

ស្តីពីការផ្ទេរការងារមន្ត្រី រាជការ របស់ក្រសួងពត៌មាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ: ០៦ ន.ស ចុះថ្ងៃទី ៣០ ខែ តុលា ១៩៩៤ ស្តីពីការ អោសប្រើប្រាស់ច្បាប់សហលក្ខន្តិកៈមន្ត្រី រាជការ ស៊ីវិល
- យោងចំណារបញ្ជូនលេខ: ៦៨ ពម ចុះថ្ងៃទី ២៦_៨_១៩៩៥ របស់មន្ទីរពត៌មានខេត្ត កំពង់ស្ពឺ
- យោងចំណារយល់ព្រមលេខ:៧៥៣ សរសណ ចុះថ្ងៃទី២៩_៨_១៩៩៥ របស់ឯកឧត្តម អភិបាល ខេត្តកំពង់ស្ពឺ
- យោងលិខិតយល់ព្រមទទួលលេខ ១៨០ ធត.វវសបុ ចុះថ្ងៃទី ១៦_៩_១៩៩៥ របស់ ឯកឧត្តម រដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ពិនិត្យតាមសំណូមពររបស់សាមីខ្លួន

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ឡឹក នាង** ជាអនុប្រធានមន្ទីរពត៌មានខេត្តកំពង់ស្ពឺ ទៅបំពេញការ ងារនៅមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ស្ពឺ នៃក្រសួងវប្បធម៌និងវិចិត្រ សិល្បៈ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ។ របស់សាមីខ្លួន ត្រូវបានទទួលនៅអង្គភាពថ្មី ចាប់ពីថ្ងៃទី ០១ ខែ តុលា ១៩៩៥ នេះតទៅ ។

ប្រការ ៣ ៈ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងពត៌មាន មន្ទីរពត៌មានខេត្តកំពង់ស្ពឺ និង សាមីខ្លួនមានភារៈអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

៧-ទីស្ដីការរដ្ឋមន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៦១ ប្រកវវស.ប្រ

ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តតាកែវ

* * *

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំផ្លាស់ប្ដូរកន្លែងធ្វើការរបស់លោក **ខ្វិត សែន** ប្រធានការិយាល័យវប្បធម៌ស្រុកដូនកែវ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តតាកែវ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : លោក **ខិក សែន** ប្រធានការិយាល័យវប្បធម៌ស្រុកជូនកែវនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តតាកែវ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកោះកុង។

មាត្រា ២ :មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តតាកែវ ត្រូវផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេង ៗ របស់សាម៉ីខ្លួននិងក្របខ័ណ្ឌមួយកន្លែងជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកោះកុង ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តតាកែវ និងលោក **ខិក សែន** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និង ត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ឃីណារ៉ា

* * *

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

ប្រកាស

ប្រកាសលេខ: ១៤៩៧ អយក.ប្រក ភ្នំពេញ,ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ៧ មករា មកជា សាលាបឋមសិក្សាពេជ្រមន្ត្រី

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០_១១_១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មេឃុំប្រសូតិ ស្រុកស្វាយទាប ខេត្តស្វាយរៀង លេខ១៨ ប.ស ចុះថ្ងៃទី ១៧_៥_១៩៩៥ និងចំណារបញ្ជូនលេខ ៧៣ ចប.ចទម ចុះថ្ងៃទី ៧ ខែ មិថុនា ១៩៩៥ របស់មន្ទីរអប់រំយុវជននិងកីឡា ខេត្តស្វាយរៀង ព្រមទាំងចំណារឯកភាពលេខ ៣៦៧ ស.កិ ចុះថ្ងៃ ទី ១២ ខែ មិថុនា ១៩៩៥ របស់អភិបាលខេត្តស្វាយរៀង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជននិងកីឡា ខេត្តស្វាយរៀង ប្តូរឈ្មោះសាលាបឋមសិក្សា ៧ មករា មកជាសាលាបឋមសិក្សា « ពេជ្រមន្ត្រី » វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥_៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : មន្ទីរ ក្រសួងអប់រំយុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជននិងកីឡា ខេត្តស្វាយរៀង និង សាលាបឋមសិក្សាពេជ្រមន្ត្រី មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តូល ឡោះ

ភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៤៩៨ អយក.ប្រក ស្តីពី ការទទួលស្គាល់សិស្ស និង ក្រុមសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ និង គណិតវិទ្យា នៃមធ្យមសិក្សាសំរាប់ឆ្នាំសិក្សា ១៩៩៤–៩៥

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញក្រឹត្យ– ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំនេះទូទៅ
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៨១ សសរ ចុះថ្ងៃទី ២៤ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា និង អក្សរសិល្ប៍ខ្មែរ
- បានឃើញបទបញ្ជាលេខ ៣៨ អរ.បប.ចទម ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៨៨ ស្តីពីការបើក ថ្នាក់សិស្សពូកែ ផ្នែកអក្សរសិល្ប៍ និង គណិតវិទ្យា និង ការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស
- យោងកំនត់ហេតុ នៃការប្រជុំរបស់គណមេប្រយោគ ប្រលងសិស្សពូកែទូទាំងប្រទេស ដែលសំរេចលើលទ្ធផលប្រលងសិស្សពូកែទូទាំងប្រទេស សម័យប្រលង ០៥ ឧសភា ១៩៩៥

សំរេច

ប្រការ១ : សិស្សពូកែថ្នាក់ទី ៨ ផ្នែកអក្សរសិល្ប៍ និង គណិតវិទ្យា និងសិស្សពូកែថ្នាក់ទី ១១ ផ្នែកគណិតវិទ្យា នៃសាលារៀនចំណេះទូទៅ ដូចមានរាយនាមខាងក្រោមត្រូវបាន ប្រកាសថា ប្រលងជាប់ជាសិស្សពូកែទូទាំងប្រទេស :

ក . ថ្នាក់ទី ៨

១ . ផ្នែកអក្សរសិល្ប៍ :

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃ ខែ ឆ្នាំកំណើត	ខេត្ត-ក្រុង
១	ភួង ស៊ីណាត	ស្រី	១២-៩-៨២	បាត់ដំបង
២	សាយ លក្ខិណា	ស្រី	១៦-១០-៨០	កំពង់ស្ពឺ
៣	រេត វុទ្ធី	ប្រុស	០៧-១១-៧៩	បាត់ដំបង
៤	ភី សុកន្និដ្ឋា	ស្រី	១២-១០-៨០	កំពង់ឆ្នាំង

១ . ផ្នែកគណិតវិទ្យា

ល.រ	គោត្តនាមនិងនាម	ភេទ	ថ្ងៃ ខែ ឆ្នាំកំណើត	ខេត្ត-ក្រុង
១	ហេង ចរ់ាវ	ស្រី	២៦-៩-៨០	បាត់ដំបង
២	ប៊ុត ប៉ូរីវិចិត្រ	ប្រុស	២០-៥-៨១	កំពង់ឆ្នាំង
៣	នង សុវណ្ណៈ	ប្រុស	២០-០១-៨១	ពោធិសាត់
៤	វ៉ា លួងខាំផា	ស្រី	១១-១២-៨០	កំពង់ធំ
៥	ឯក គង់	ប្រុស	១៧-៩-៨០	កំពង់ធំ
៦	ពៅ សត្យា	ប្រុស	០១-០១-៨១	កំពង់ឆ្នាំង
៧	សាកេត អេលីដា	ស្រី	០២-០២-៨១	កំពង់ឆ្នាំង
៨	ជី ទេវិទ្ធ	ប្រុស	០៤-០២-៨១	កំពង់ធំ
៩	សោម សុធា	ប្រុស	០៩-១០-៨០	កំពង់ធំ
១០	តាន់ ហ៊ាងសីហា	ប្រុស	១៣-៨-៨១	កំពង់ធំ

ខ . ថ្នាក់ទី ១១

ផ្នែកគណិតវិទ្យា

ល.រ	គោត្តនាមនិងនាម	ភេទ	ថ្ងៃ ខែឆ្នាំកំណើត	ខេត្ត-ក្រុង
១	ជា ផារីទ្ធ	ប្រុស	០៦-៥-៧៩	រ.ព្រះស៊ីហនុវត្ថិ
២	ស៊ឹង ថុល	ប្រុស	០៨-៤-៧៧	កំពង់ចាម
៣	សុខ ធារី	ស្រី	០៧-៥-៧៨	រ.ព្រះស៊ីហនុវត្ថិ

៤	ជា លក្ខិណា	ស្រី	១២-៤-៧៩	វិ.ព្រះស៊ីសុវត្ថិ
៥	ជា លាងខេង	ប្រុស	១២-០២-៧៧	វិ.ព្រះស៊ីសុវត្ថិ

ប្រការ ២ : ត្រូវបានកំណត់ថា ជាជ័យលាភីសិស្សពូកែ និង ក្រុមសិស្សពូកែថ្នាក់ទី ៨ និង ថ្នាក់ទី ១១ ផ្នែក អក្សរសិល្ប៍ និង គណិតវិទ្យា ដូចតទៅ :

ក . សំរាប់ថ្នាក់ទី ៨ :

I . ជ័យលាភីសំរាប់សិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ :

លេខ ១	ក.ភួង ស៊ីណាត	បាត់ដំបង
លេខ ២	ក.សាយ លក្ខិណា	កំពង់ស្ពឺ
លេខ ៣	រ៉េត វុទ្ធី	បាត់ដំបង
រង្វាន់លួងចិត្ត	ក.ភី សុគន្ធិដ្ឋា	កំពង់ឆ្នាំង

II . ជ័យលាភីសំរាប់សិស្សពូកែទូទាំងប្រទេសផ្នែក គណិតវិទ្យា :

- លេខ ១ : ក.ហេង ប៉ាវ បាត់ដំបង
- លេខ ២ : ប៊ុត បូរីវិចិត្រ កំពង់ឆ្នាំង
- លេខ ៣ : នង សុវណ្ណៈ ពោធិសាត់
- រង្វាន់លួងចិត្ត : ក.រ៉ា លួងខាំផា កំពង់ធំ

III . ជ័យលាភីសំរាប់ក្រុមសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ :

- លេខ ១: គ្មាន
- លេខ ២: គ្មាន
- លេខ ៣ : ខេត្តបាត់ដំបង-សៀមរាប-កណ្ដាល

IV . ជ័យលាភីសំរាប់ក្រុមសិស្សពូកែទូទាំងប្រទេស ផ្នែកគណិតវិទ្យា :

- លេខ ១: គ្មាន
- លេខ ២: គ្មាន
- លេខ ៣ : ខេត្តកំពង់ឆ្នាំង

ខ-សំរាប់សិស្សថ្នាក់ទី ១១ :

I ជ័យលាភីសំរាប់សិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ :

- គ្មាន

II. ជ័យលាភីសំរាប់សិស្សពូកែទូទាំងប្រទេស ផ្នែកគណិតវិទ្យា :

–លេខ ១: ជា ធារីទ្ធ វិទ្យាល័យព្រះស៊ីសុវត្ថិ

–លេខ ២: ស៊ីង ថុល កំពង់ចាម

–លេខ ៣ : ក.សុខ ធារី វិទ្យាល័យព្រះស៊ីសុវត្ថិ

–រង្វាន់លួងចិត្ត : ក.ជា លក្ខិណា វិទ្យាល័យព្រះស៊ីសុវត្ថិ

III. ជ័យលាភីសំរាប់ក្រុមសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ :

–គ្មាន

IV. ជ័យលាភីសំរាប់ក្រុមសិស្សពូកែទូទាំងប្រទេស ផ្នែកគណិតវិទ្យា :

– គ្មាន

ប្រការ ៣ : សិស្សពូកែ និង ក្រុមសិស្សពូកែថ្នាក់ទី ៨ និង ថ្នាក់ទី ១១ ជាជ័យលាភីទូទាំងប្រទេស ដូចមាន ចែងក្នុងប្រការ ២ ខាងលើ ត្រូវបានទទួលប្រាក់រង្វាន់តាមប្រការ ១១ សេចក្តីសំរេចក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៨១ សសរ ចុះថ្ងៃទី ២៤ មិថុនា ១៩៨៧ ដូចតទៅ :

១–រង្វាន់សំរាប់សិស្សពូកែម្នាក់ ។ :

–សិស្សលេខ ១ ម្នាក់ ។ ត្រូវទទួលរង្វាន់ជាប្រាក់ ៤០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ៥០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

–សិស្សលេខ ២ ម្នាក់ ។ ត្រូវទទួលរង្វាន់ជាប្រាក់ ៣០០ រៀលសំរាប់មធ្យមសិក្សាកំរិត ១ និង ៤០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

– សិស្សលេខ ៣ ម្នាក់ ។ ត្រូវទទួលរង្វាន់ជាប្រាក់ ២០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ៣០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

– សិស្សលួងចិត្តម្នាក់ ។ ត្រូវទទួលរង្វាន់ជាប្រាក់ ១០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ១៥០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

២–រង្វាន់សំរាប់ក្រុមសិស្សពូកែនីមួយ ។ :

–ក្រុមលេខ ១ នីមួយ។ ត្រូវទទួលរង្វាន់ជាប្រាក់ ១.៥០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ២.០០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

–ក្រុមលេខ ២ នីមួយ។ ត្រូវទទួលរង្វាន់ជាប្រាក់ ១.០០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ១.៥០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

-ក្រុមលេខ ៣ នីមួយៗ ត្រូវទទួលរង្វាន់ជាប្រាក់ ៥០០ រៀល សំរាប់មធ្យមសិក្សាកំរិត ១ និង ១.០០០ រៀល សំរាប់មធ្យមសិក្សាកំរិត ២ ។

ប្រការ ៤ : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា លោកប្រធាន នាយកដ្ឋានផែនការ- ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡាគ្រប់អង្គភាពពាក់ព័ន្ធ មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៥០២ អយក.ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ រំពឹល នៅជា «អនុវិទ្យាល័យសម្តេច ជា ស៊ីម»

នៅខេត្ត ស្វាយរៀង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ នេះទូទៅ
- បានឃើញសេចក្តីសំរេចលេខ ២៥៣ អរ.សសរ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ស្តីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ នៅខេត្តស្វាយរៀង

- យោងសំនើរបស់មន្ទីរអប់រំយុវជន និង កីឡាខេត្ត ស្វាយរៀង ស្តីពីការសុំប្តូរឈ្មោះ អនុវិទ្យាល័យ អំពិលទៅជា «អនុវិទ្យាល័យសម្តេច ជា ស៊ីម » ដោយមានការឯកភាពពី អភិបាលខេត្តស្វាយ រៀង ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ អំពិលបច្ចុប្បន្នទៅជា «អនុវិទ្យាល័យសម្តេច ជា ស៊ីម» ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក និង ប្រធាន នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៥ - ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

ភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ : ១៨៩/៩៥ កធស

ស្តីពីការអនុញ្ញាតឲ្យបើកទទួលស្គាល់គ្រិស្តសាសនា នៃ

« ក្រុមជំនុំព្រះគុណ »

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋ មន្ត្រី និងទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញពាក្យសុំអនុញ្ញាតច្បាប់ធ្វើសកម្មភាពគ្រិស្តសាសនា «នៃក្រុមជំនុំព្រះគុណ » ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយមានស្នាក់ការគ្រិស្តបរិស័ទរបស់ « ក្រុមជំនុំព្រះគុណ» មួយកន្លែងស្ថិតនៅក្រុមទី ២៦ ភូមិវត្តរំដួល ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : « ក្រុមជំនុំព្រះគុណ » ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជា សាសនាសុទ្ធសាធ ។

ប្រការ ៣ : « ក្រុមជំនុំព្រះគុណ » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា. សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : « ក្រុមជំនុំព្រះគុណ » ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ. រាល់ការអនុវត្តផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តន៍ សេចក្តីសំរេចខាងលើនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀន វណ្ណារិទ្ធ

ភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ១៩០/៩៥ ក.ធ.ស

«ស្តីពីការអនុញ្ញាតច្បាប់អោយបើកស្នាក់ការសាខាអង្គការនិស្សិត និងប្រជារាស្ត្រខ្មែរថ្វាយព្រះគ្រិស្ត នៅខេត្តពោធិសាត់ »

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ១ និង នាយករដ្ឋមន្ត្រីទី ២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសំណើសុំបើកសាខាទីស្នាក់ការ អង្គការនិស្សិតនិងប្រជារាស្ត្រខ្មែរថ្វាយព្រះគ្រិស្ត
- ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

សរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយមានស្នាក់ការសាខារបស់ "អង្គការនិស្សិត និងប្រជារាស្ត្រ ខ្មែរថ្វាយព្រះគ្រិស្ត " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ទីរួមខេត្តពោធិសាត់ ។

ប្រការ ២ : ស្នាក់ការសាខា នៃអង្គការនិស្សិត និង ប្រជារាស្ត្រខ្មែរថ្វាយព្រះគ្រិស្ត ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយ នូវលទ្ធិសាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ស្នាក់ការសាខា នៃអង្គការនិស្សិត និង ប្រជារាស្ត្រខ្មែរថ្វាយព្រះគ្រិស្ត ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ សន្ធាជាត់ គមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ ...ម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាម ច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះ មានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀង ធណ្ណារ័ត្ន

* * *

ភ្នំពេញ,ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ:១៩១/៩៥ កធស.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។
- បានឃើញលិខិតលេខ ៣៤-៩៥ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង ។

សំរេច

ប្រការ ១ : តែងតាំងលោក ឌេត ឆន បច្ចុប្បន្នគ្រូពុទ្ធិកបឋមសិក្សា ជាប្រធានការិយាល័យសាសនះសិក្សា ។

-កញ្ញា **ចាន់ ថាវី** បច្ចុប្បន្នជាបុគ្គលិកការិយាល័យរដ្ឋបាល ជាអនុប្រធានការិយាល័យរដ្ឋបាល ទទួលការងារបេឡាធិការ ។

ប្រការ ២ : មន្ទីរធម្មការ និង សាសនាខេត្ត មន្ទីរហិរញ្ញវត្ថុខេត្ត មន្ទីរផែនការខេត្តកំពង់ឆ្នាំង លោក និងកញ្ញា ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តរៀង ៗ ខ្លួនតាមសេចក្តីប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារិទ្ធ

* * *

៦ - ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

ភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ :១១០ ប្រក.ផក

ស្តីពីការទទួលស្គាល់ការិយាល័យផែនការក្រុងកែប មកជាមន្ទីរ ផែនការក្រុងកែប

* * *

រដ្ឋមន្ត្រី ក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូរឋានាសម្ព័ន្ធរដ្ឋបាលក្រុងកែប ពីថ្នាក់ស្រុកមកថ្នាក់ក្រុង ។

សម្រេច

ប្រការ ១ : ទទួលស្គាល់ការិយាល័យផែនការក្រុងកែប ជាមន្ទីរផែនការក្រុងកែប ។

ប្រការ ២ : មន្ទីរផែនការក្រុងកែប ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ក្រសួងផែនការ ។

ប្រការ ៣ : មន្ទីរផែនការក្រុងកែប ត្រូវមានការិយាល័យជំនាញផ្សេងៗជាចំណុះ ។

ប្រការ ៤ : លោកប្រធានមន្ទីរ លោកប្រធានអង្គភាពដែលមានការពាក់ព័ន្ធលោកប្រធានមន្ទីរផែនការក្រុងកែប មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ជា ចាន់តូ

* * *

៧ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

ភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥២ ចក.ស្តីពីការ

ផ្ទេរមន្ត្រី បុគ្គលិករាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤

- បានឃើញកិច្ចព្រមព្រៀងក្រុមប៉ុទចំរុះរវាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងក្រុមហ៊ុន អាំងដូសាត ស្តីពីការស្តារ និងពង្រីកអគីតបណ្តាញទូរគមនាគមន៍ អ៊ុនតាក់ នៅព្រះរាជាណាចក្រ កម្ពុជា
- បានឃើញលិខិតលេខ **124/YMD/CMD/95** ចុះថ្ងៃទី ១៥-៩-១៩៩៥ របស់ក្រុមហ៊ុនខាំមីន តែល

សម្រេច

ប្រការ ១ : បញ្ជូនមន្ត្រីបុគ្គលិករាជការចំនួន ០៤រូប នៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ អោយទៅបំរើការ១ ងារនៅក្រុមហ៊ុនខាំមីនតែល ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ។

១- លោក	**មាស ចរិយា**	បតិត្ថាហកៈរងទទួលបន្ទុករួម
២- លោក	**ពេជ គី**	អ្នកបច្ចេកទេស
៣- លោក	**ម៉ិន ចាន់ថាន**	-
៤- លោក	**គុយ ស៊ីណូ**	-

ប្រការ ២ : មន្ត្រីរាជការដែលមានចែងក្នុងប្រការ ១ ខាងលើនេះ ត្រូវទទួលប្រាក់បៀវត្សពីក្រុមហ៊ុន ខាំមីនតែល ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ ។ ឯប្រាក់បៀវត្សដែលបានទទួលពីក្រសួង ឬ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកំពង់ធំនោះត្រូវបង្វែរចូលថវិកាក្រសួងឬខេត្តវិញ ។ ចំពោះក្របខ័ណ្ឌសាមីខ្លួនក្រសួងត្រូវរក្សាទុក ។

ប្រការ ៣ : ដោយឡែកលោក **មាស ចរិយា** បតិត្ថាហកៈរងទទួលបន្ទុកខុសត្រូវតាមមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តកំពង់ធំ នោះក្របខ័ណ្ឌ និង ប្រាក់បៀវត្សរក្សាទុកដដែលគ្រាន់តែទទួលប្រាក់ការកិច្ច បន្ថែមលើការងារសព្វថ្ងៃ ។ រីឯការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម គឺអាស្រ័យទៅលើក្រុមហ៊ុន « ខាំមីន តែល » ជាអ្នកផ្តល់ទៅតាមសមត្ថភាព និង លទ្ធភាពនៃការងារ ។

ប្រការ ៤ : ខុទ្ទកាល័យ.អធិការដ្ឋាន ,នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច ,នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស និង មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តកំពង់ធំ និង សាមីខ្លួនទាំង ០៤ នាក់ ខាងលើត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃដូចមានចែងក្នុងប្រការ ១ ខាងលើ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សុ ឃុន

* * *

ភ្នំពេញ,ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២០ បទ.ប្រក

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥–៣–១៩៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញប្រកាសលេខ ២០៥ បទប្រកទម ចុះថ្ងៃទី ១២–១២–១៩៩៤
- បានឃើញពាក្យស្នើសុំឈប់ប្រើប្រាស់វិទ្យុប្រភេទ HF ចុះថ្ងៃទី ០៨–៩–១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉េង សោ** ផ្អាកឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៣ គ្រឿង ។

ប្រការ ២ : ប្រកាសលេខ ២០៥ បទប្រកទម ចុះថ្ងៃទី ១២–១២–១៩៩៤ ទុកជានិរាករណ៍

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការ គណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងលោក **ម៉េង សោ** ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សុ ឃុន

ភ្នំពេញ,ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២១ បទ.ប្រក

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-១៩៨៧ ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ២០៦ បទប្រកទអ ចុះថ្ងៃទី ១២-១២-១៩៩៤
- បានឃើញពាក្យស្នើសុំប្តូរទីតាំងប្រើប្រាស់វិទ្យុប្រភេទ VHF ចុះថ្ងៃទី ០៨-៩-១៩៩៥ របស់លោក **ម៉េង ឆោ** ប្រធានក្រុមហ៊ុន ណុបផាវង្ស ខុនស្រ្តាក់សិន ចំកាត់

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន **ណុប ផាវង្ស** ខុនស្ត្រាក់សិនចំកាត់ ប្តូរទីតាំងប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០២ គ្រឿងពីផ្ទះលេខ ១៣៤ ផ្លូវ ១២២ ស.កទឹកល្អក់ មកផ្ទះលេខ ២២ ផ្លូវ ២៨៧ សង្កាត់ បឹងកក់ ១ ខ័ណ្ឌទួលគោក ។

ប្រការ ២ : ប្រកាសលេខ ២០៦ បទប្រកទអ ចុះថ្ងៃទី ១២-១២-១៩៩៤ ទុកជានិរាករណ៍

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍ អន្តរជាតិ និងលោក **ម៉េង ឆោ** ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

សូ ឃុន

* * *

ភ្នំពេញ,ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២២ មខ.ប្រក

អនុញ្ញាតអោយក្រុមហ៊ុនកម្ពុជា ស៊ីណាវ៉ាត្រា

ផ្អាកឈប់ប្រើវិទ្យុទាក់ទងប្រភេទ VHF

-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៩-៣-១៩៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញប្រកាសលេខ ០៩១ បទក្រប្រក ចុះថ្ងៃទី ១០-៨-១៩៩៤
- បានឃើញពាក្យស្នើសុំឈប់ប្រើប្រាស់វិទ្យុប្រភេទ HF ចុះថ្ងៃទី ០៨-៩-១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនកម្ពុជាស៊ីណាវ៉ាត្រាផ្អាកឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៦ គ្រឿង ។

ប្រការ ២ : ប្រកាសលេខ ០៩១ បទក្រប្រក ចុះថ្ងៃទី ១០-៨-១៩៩៤ ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការ គណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍ អន្តរជាតិ និងលោក ម៉ែន នោ ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា ៣៉ាង ត្រា

សូ ឃុន

* * *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៥២ រៀល